# រឿងជោគជ័យលេចធ្លោ ឃុំអូរតាគី



| | |
|---|---|
| ឈ្មោះគម្រោង | លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (PROCEDD) |
| ចំណងជើងរឿង | ផ្កាវិកជាយក្រុង |
| កាលបរិច្ឆេទនៃការកត់ត្រា | ១០ មិនា ២០១៥ |
| រឿងនោះកើតឡើងនៅពេលណា | ចាប់តាំងពីឆ្នាំ២០១៣ |
| ឈ្មោះភូមិ ឬឈ្មោះស្រុក<br>(ទីកន្លែងដែលរឿងបានកើតឡើង) | ភូមិ ត្រស់ ឃុំ អូរតាគី |
| ឈ្មោះអ្នកនិយាយរឿងប្រាប់ | កញ្ញា ញ៉ិ លីនណា<br>អនុប្រធានបណ្ដាញអង្គការសហគមន៍មូលដ្ឋាន |
| ▼ -ចំនួនអ្នកទទួលផល | |
| ▼<br>▼ -អាយុជាមធ្យម(បុរស ឬស្ត្រី ) | ២៣ ឆ្នាំ |
| អ្នកសំរបសំរួល (តួនាទី ទីតាំង) | កញ្ញា ជិន ចិន្តា បុគ្គលិកគម្រោង PROCEED បាត់ដំបង |
| អ្នកកត់ត្រា (តួនាទី ទីតាំង) | លោក វ៉ាន ភាន់ បុគ្គលិកគម្រោង PROCEED បាត់ដំបង |

**<u>ពិពណ៌នារឿង</u>**



កញ្ញា **ញ៉ិ លីនណា** អាយុ២៣ឆ្នាំ រស់នៅភូមិត្រស់ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង។ **លីនណា** ជាយុវនារីមួយរូបដែលរស់នៅក្រោមបន្ទុកឪពុកម្ដាយក្នុងជីវភាពខ្វះខាត។ ដោយកត្តាជីវភាពខ្វះខាត និងសាលានៅឆ្ងាយពីផ្ទះផង បានជម្រុញ **លីនណា** សំរេចចិត្តបោះបង់ការសិក្សាត្រឹមតែថ្នាក់ទី១០។

ក្រោយពីបានបោះបង់ការសិក្សា **លីនណា** បានប្រកបមុខរបរធ្វើស្រែ និងដាំបន្លែជាមួយឪពុកម្ដាយដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាព។ ក្នុងអំឡុងពេលនោះ **លីនណា** មិនដែលបានយកចិត្តទុកដាក់និងគិតគូរពីការងារសហគមន៍ ឬការអភិវឌ្ឍសង្គមអ្វីឡើយ។ កាលពីមុន **លីនណា** មិនដែលស្គាល់ទីតាំងសាលាស្រុក រឺក៏សាលាឃុំឡើយ។ រាល់ពេល **លីនណា** ចូលរួមក្នុងសកម្មភាពផ្សេងៗដែលរៀបចំនៅក្នុង ភូមិ ឃុំ **លីនណា** មិនហ៊ានបញ្ចេញយោបល់ទេ ដោយសារ **លីនណា** គិតថាខ្លួនមានភាពវ័យក្មេងជាងប្រជាពលរដ្ឋ និងអង្គការសហគមន៍មូលដ្ឋានផ្សេងទៀត។

នៅឆ្នាំ២០១៣ សមាជិកបណ្ដាញអង្គការសហគមន៍ ក្នុងស្រុកថ្មគោល បានបោះឆ្នោតជ្រើសរើស **លីនណា** ជាអនុប្រធានបណ្ដាញអង្គការសហគមន៍មូលដ្ឋាន ប្រចាំស្រុក។ ក្នុងតួនាទីនេះ លីនណានិងសហការអនុវត្តគម្រោងជាមួយក្រុមប្រឹក្សាស្រុកនៃគម្រោង "***លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ***" ហៅកាត់ថា (PROCEED) សម្របសម្រួលដោយអង្គការ ក្រុមទ្រទ្រង់ភូមិ ឧបត្ថមមូលនិធិពី "*ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍរបស់ប្រទេសស៊ុយអែត*" តាមរយៈអង្គការផេកកម្ពុជា។

**លីនណា** បានទទួលការបង្ហាត់បង្ហាញនិងសម្របសម្រួលជាប្រចាំដោយអង្គការដៃគូ និងបានទទួលការបណ្ដុះបណ្ដាលជាច្រើនពីគម្រោងរួមមាន៖ សិទ្ធិជាមូលដ្ឋាន ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលដ្ឋក្នុងដំណើរការអនុវត្តគម្រោង តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ជំនាញសម្របសម្រួលសហគមន៍ ជំនាញនិយាយសាធារណៈ ការរកៀគរប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សា។ល។ ក្រៅពីនេះលីនណាបានលើកទឹកចិត្តឱ្យប្រជា

ពលរដ្ឋចូលរួមក្នុងកិច្ចពិគ្រោះយោបល់មូលដ្ឋាន វេទិកាសាធារណៈ ដើម្បីឱ្យប្រជាពលរដ្ឋមានឱកាសលើកឡើងពីបញ្ហា និងតម្រូវការជូនក្រុមប្រឹក្សាដោះស្រាយ ។

ក្រោយពី **លីនណា** ទទួលបានចំណេះដឹង បទពិសោធន៍ពីការអនុវត្តគម្រោង PROCEED **លីនណា** មានភាពក្លាហាន ម៉ានបញ្ចេញមតិយោបល់ជួសឱ្យសហគមន៍ និងសកម្មចូលរួមអនុវត្តគម្រោងជាមួយក្រុមប្រឹក្សាផងដែរ។ **លីនណា** បានកៀរគរប្រជាពលរដ្ឋ ជាពិសេស ស្ត្រី យុវជន ក្រុមជនងាយរងគ្រោះឱ្យចូលរួមក្នុងសកម្មភាពពិគ្រោះយោបល់ក្រុមប្រឹក្សាឃុំ ស្រុក សហការជាមួយប្រធានបណ្ដាញ និងសមាជិកអង្គការសហគមន៍មូលដ្ឋានប្រចាំស្រុកថ្មគោល រៀបចំវេទិកាអង្គការសហគមន៍មូលដ្ឋាន កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ និងកម្មវិធីម៉ោងជួបប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សា។ **លីនណា** តែងតែលើកទឹកចិត្តឱ្យប្រជាពលរដ្ឋជាពិសេសស្ត្រី យុវជន ក្រុមជនងាយរងគ្រោះលើកពីបញ្ហា និងតម្រូវការជូនក្រុមប្រឹក្សាដោះ ស្រាយ និងជាពិសេសប្រជាពលរដ្ឋដែលមានបញ្ហា ។

លើសពីនេះ **លីនណា** មិនត្រឹមតែបានចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីកិច្ចប្រជុំពិភាក្សាតុមូលក្នុងការពិភាក្សាអំពីអភិបាលកិច្ចមូលដ្ឋាន និងបញ្ហាជាអាទិភាពក្នុងសហគមន៍ ថែមទាំងបានធ្វើជាអ្នកសម្របសម្រួលក្នុងការផ្សព្វផ្សាយចំណេះដឹងបន្តដល់ប្រជាពលរដ្ឋ ពីសិទ្ធតួនាទី របស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាដល់សហគមន៍ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានផងដែរ។

ដោយសារទទួលបានបទពិសោធន៍នៃការអនុវត្តគម្រោង PROCEED និងបានចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាជាច្រើនមក **កញ្ញា ញ៉ិ លីនណា** ម៉ានលើកឡើងពីបញ្ហាអាទិភាពមួយចំនួនជូនក្រុមប្រឹក្សាស្រុក ឃុំ ដើម្បីដោះស្រាយ **លីនណា** បានលើកពីបញ្ហាផ្លូវពិបាកធ្វើដំណើរពីវត្តត្រស់ ទៅដល់ ផ្លូវជាតិលេខ៥ មានចំ**ងាយ ២,៧០០ម៉ែត្រ** បញ្ហាផ្លូវពិបាកធ្វើឱ្យអោយប្រជាពលរដ្ឋក្នុងភូមិពិបាកក្នុងការដឹកកសិផលទៅកាន់ទីផ្សារ រីឯសិស្សានុសិស្ស ពិបាកធ្វើដំណើរទៅកាន់សាលា។ កញ្ញាក៏បានលើកបញ្ហាមួយទៀតគឺ <u>**ការខ្វះពូជបន្លែ**</u> ដែលជាកត្តាជម្រុញឱ្យប្រជាពលរដ្ឋក្នុងភូមិចំណាកស្រុកច្រើន។ **លីនណា** បានលើកបញ្ហា ទាំងនេះដដែល។ ចំនួន៣ដងក្នុងវេទិការបស់ក្រុមប្រឹក្សាស្រុក និងឃុំ និងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា ឃុំ ដើម្បីជូនក្រុមប្រឹក្សាជួយដោះស្រាយជាបន្ទាន់។ ជាលទ្ធផល ក្រុមប្រឹក្សាបានសហការជាមួយអង្គការដៃគូបានជួសជុលផ្លូវដែលពិបាកធ្វើដំណើរ ដែលធ្វើឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរបានស្រួលជាងមុន ចំណែកឯប្រជាពលរដ្ឋចំនួន**៩០គ្រួសារ** បានទទួលគ្រាប់ពូជ ស្រូវ ដំណាំ បន្លែ ស្ពៃ ត្រកួន ត្រសក់ សណ្ដែកគួរ។ល។ លើសពីនេះ **លីនណា** ក៏បានចូលរួមជាមួយក្រុមយុវជនក្នុង ភូមិ និងក្រៅភូមិផ្សេងទៀតចំនួន **២៣នាក់** ដើម្បីលើកឡើងនូវបញ្ហា ជូនក្រុមប្រឹក្សា ដោះស្រាយបញ្ហា

| |
|---|
| ជូនដល់គ្រួសារងាយរងគ្រោះ និងរងគ្រោះដោយសារ ទឹកជំនន់ក្នុងឃុំផងដែរ ។<br>លោក **ភន សារី** ជាប្រជាពលរដ្ឋភូមិត្រស់ បានមានប្រសាសន៍ថា "ដោយសារតែការខិតខំប្រឹងប្រែងរបស់កញ្ញា ញ៉ិ **លីនណា** ក្នុងការលើកឡើងពីបញ្ហា និងចូលរួមតស៊ូមតិ ទាំងនេះហើយទើបគាត់អាចទទួលបានផ្លូវធ្វើដំណើរស្រួលជាងមុន និងមានគ្រាប់ពូជសម្រាប់ដាំដើម្បីផ្គត់ផ្គង់ជីវភាពបែបនេះ។ នេះជាមោទនភាពមួយក្នុងភូមិរបស់គាត់ ដែលមានយុវនារីដ៏ក្លាហានបែបនេះទោះ ទោះជាមិនទាន់បានជួយដល់គាត់ ១០០%ក៏ដោយចុះ ក៏គាត់រំពឹងថានឹងអាចជួយភូមិគាត់បានល្អប្រសើរជាងនេះទៀត" ។<br>ការផ្លាស់ប្តូរដែលគួរអោយកត់សំគាល់គឺ **កញ្ញា លីនណា** ជាយុវនារីក្លាហាន ហ៊ានលះបង់ពេលវេលាជួយការងារសង្គម គិតគូរពីផលប្រយោជន៍សហគមន៍ ហ៊ានលើកឡើងពីបញ្ហាតម្រូវការរបស់ប្រជាពលរដ្ឋជូនក្រុមប្រឹក្សាស្រុក ឃុំ។ **លីនណា** ជាយុវនារីដែលមានភាពជាអ្នកដឹកនាំក្នុងសហគមន៍ និងមានចំណេះដឹងទូទៅសមរម្យ។ ទោះជាការងារខ្លះថ្មីសុទ្ធសាធសំរាប់ **លីនណា** ក៏**លីនណា** នៅតែប្តេជ្ញាថា និងប្រឹងប្រែងបន្តកាងារនេះ និងរៀនសូត្របន្ថែមពីចាស់ទុំជាតំណាងអង្គការសហគមន៍មុនៗ និងអ្នកដទៃផ្សេងទៀតដើម្បីជួយសហគមន៍។ |
| **<u>ការសង្កេតលើចំណុចសំខាន់ៗ៖ កាយវិការ អារម្មណ៍ អត្តចរិករបស់អ្នកចូលរួម</u>**<br>កញ្ញា ញ៉ិ លីនណា មានជំនឿ ចំណេះដឹង និងមានអារម្មណ៍សប្បាយរីករាយក្នុងការផ្តល់ព័ត៌មាន |
| **<u>វិស័យ៖</u>**:អភិបាលកិច្ចមូលដ្ឋាន |